**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៨០ សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការកំណត់តួនាទី និងភារកិច្ចរបស់ទីប្រឹក្សាជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍ជនបទ

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១១៦១ អនក្រ.តត ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អាណត្តិទី៦ និងទីប្រឹក្សាជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់តួនាទី និងភារកិច្ចរបស់ឯកឧត្តម **សុន គន្ធរ** ទីប្រឹក្សាជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍ជនបទដូចតទៅ÷

១. ផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាល និងអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទលើ÷

- កិច្ចការកែទម្រង់ធនាគារអភិវឌ្ឍន៍ជនបទ
- គោលនយោបាយទ្រទ្រង់និងអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម និងមីក្រូហិរញ្ញវត្ថុ
- គោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យស្រូវ-អង្ករ និង
- កិច្ចការផ្សេងទៀតតាមសំណូមពររបស់ក្រុមប្រឹក្សាភិបាល ឬអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ។

២. ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីផ្តល់យោបល់តាមការចាំបាច់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត ឬសិទ្ធិសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទេ។

៣. ចូលរួមប្រជុំនិងផ្តល់យោបល់ជូនគណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្មតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

៤. ចូលរួម ឬបំពេញបេសកកម្មក្នុងក្របខណ្ឌធនាគារអភិវឌ្ឍន៍ជនបទ តាមសំណូមពររបស់ក្រុមប្រឹក្សាភិបាល ឬអគ្គនាយក ឬដោយមានការឯកភាពពីអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ។

**ប្រការ២.-**

ក្នុងការបំពេញតួនាទីជាទីប្រឹក្សាជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍ជនបទ ឯកឧត្តម **សុន គន្ធរ** នឹងទទួលបានប្រាក់លាភការប្រចាំខែ និងរបបបេសកកម្មសម្រាប់កិច្ចការប្រតិបត្តិក្នុងក្របខណ្ឌធនាគារអភិវឌ្ឍន៍ជនបទតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ